| **៤.២ សហគមន៏អណ្តូង** | **សហគមន៏អណ្តូងៈ** ក្រុមការងារតាមផ្ទះ មណ្ឌលយុវវ័យខ្ញុំនិងអ្នក និងមជ្ឈមណ្ឌលផលិតកម្មមួយកំពុងដំណើរការគោលដៅជាក់លាក់សម្រាប់សមាគមន៏អណ្តូងៈ<br><br>**ក្រុមតាមផ្ទះ (សហគមន៏)**<br>- ក្រុមតាមផ្ទះនឹងផ្តល់សេវាចំនួន ៤៥,០០០ ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៨០០ នាក់ នៃក្រុមតាមផ្ទះ នឹងទទួលបានសេវាទាំងនោះ<br>- អាណាព្យាបាលចំនួន ៦០០នាក់ នឹងទទួលបានសេវាទាំងនោះ<br>- ផ្តល់សេវានៃការអប់រំបំណិនជីវិតបានចំនួន ៣៥,០០០<br>- នឹងមានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ១០០ នាក់<br>- កុមារ/យុវវ័យចំនួន ១០នាក់ នឹងទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត នៅខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br><br>**មណ្ឌលយុវវ័យ (ខ្ញុំ និងអ្នក)** | **សហគមន៏អណ្តូងៈ** ក្រុមការងារតាមផ្ទះ មណ្ឌលយុវវ័យខ្ញុំនិងអ្នក និងមជ្ឈមណ្ឌលផលិតកម្មមួយកំពុង ដំណើរការមានទីតាំងក្នុងសង្កាត់គោករកា។ យើងមានបុគ្គលិកបំរើការចំនួន ១៣នាក់ (ស្រី០៥នាក់) ។<br>**ក្រុមតាមផ្ទះ (សហគមន៏)**<br>- ក្រុមតាមផ្ទះបានផ្តល់សេវាចំនួន ៥៨,០៣០ (ស្រី ២៩,៤៥៩) ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៩៣៥នាក់(ស្រី៤១៨នាក់) បានចូលរួមសកម្មភាព ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣<br>- អាណាព្យាបាលចំនួន ៩៥១នាក់(ស្រី៥៤២នាក់) បានចូលរួមសកម្មភាព ចាប់ពីថ្ងៃ ទី១ ខែមករា ឆ្នាំ២០១៣<br>- ផ្តល់សេវានៃការអប់រំបំណិនជីវិតបានចំនួន ៣៦,២៦៧ (ស្រី២០,១៤២) ដង<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ១០០នាក់ (ស្រី៥៥នាក់) ក្នុងនោះមានសមាជិកសុវត្ថិភាពកុមារសហគមន៏ចំនួន ៦៨នាក់(ស្រី៥៥នាក់)<br>- យុវវយ័ចំនួន ២៩នាក់ (ស្រី១៩នាក់) ទទួលបានគាំទ្រក្នុងការទទួលសំបុត្រកំណើត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- យុវវ័យ ០៣នាក់ (ស្រី០២នាក់) សមាហរន្តកម្មទៅការងារភ្លាមៗ នៅភ្នំពេញ ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- កុមារាចំនួន ០១នាក់ បានសមាហរន្តកម្មទៅកាន់គ្រួសារនៅ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>**មណ្ឌលយុវវ័យ(ខ្ញុំ និងអ្នក)** |

| | | |
|---|---|---|
| | - ក្រុមតាមផ្ទះនឹងផ្តល់សេវាចំនួន ៤០,០០០ ដល់ក្រុមគោលដៅ (សង្គ្រោះបឋម បំណិនជីវិត អប់រំក្រៅប្រព័ន្ធ និងសកម្មភាពកម្សាន្តសប្បាយ)<br>- ផ្តល់សេវានៃការអប់រំបំណិនជីវិតបានចំនួន ២៥,០០០<br>- កុមារ/យុវវ័យចំនួន ៣០០ នាក់នៅក្នុងមជ្ឈមណ្ឌល នឹងទទួលបានសេវាទាំងនោះ<br>- អាណាព្យាបាលចំនួន៤០០នាក់ នៅក្នុងមជ្ឈមណ្ឌល នឹងទទួលបានសេវាទាំងនោះ | - ក្រុមតាមផ្ទះបានផ្តល់សេវាចំនួន ៥៣,៥១៥(ស្រី ២៦,៩២៣នាក់) ដល់ក្រុមគោលដៅ (សង្គ្រោះបឋម បំណិនជីវិត អប់រំក្រៅប្រព័ន្ធ និងសកម្មភាពកម្សាន្តសប្បាយ)<br>- ផ្តល់សេវានៃការអប់រំបំណិនជីវិតបានចំនួន ២៦,៧២៤ (ស្រី១៤,៦០៩) ដង<br>- កុមារ/យុវវ័យចំនួន ៧០១នាក់ (ស្រី២៩៩នាក់) បានចូលរួម សកម្មភាព ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣<br>- អាណាព្យាបាលចំនួន ៤៩៥នាក់ (ស្រី៣៣៩នាក់) បានចូលរួម សកម្មភាព ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ |
| | **មណ្ឌលអប់រំ**<br>- មជ្ឈមណ្ឌលអប់រំបានផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារ ៥០នាក់ ក្នុងមួយឆ្នាំ<br>- កុមារចំនួន ៣០នាក់បានគាំទ្រនិងផ្ញើសមាហរណកម្ម ទៅសាលារដ្ឋក្នុងឆ្នាំនេះ | **មណ្ឌលអប់រំ**<br>- មជ្ឈមណ្ឌលអប់រំបានផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារ ១១២នាក់ (ស្រី៦១នាក់) នៅមជ្ឈមណ្ឌលអប់រំ ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កុមារចំនួន ៤១នាក់ (ស្រី១៧នាក់) បានគាំទ្រនិង ផ្ញើសមាហរណកម្មទៅសាលារដ្ឋចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ |
| | **សិប្បកម្មតាមផ្ទះ**<br>- គ្រួសារ ៤៥នាក់ (រួមបញ្ចូល០៥គ្រួសារថ្មី) ចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមាន កុមារចំនួន១៧០នាក់ក្នុងឆ្នាំនេះ<br>- គ្រួសារចំនួន ១០ គ្រួសារ នឹងបំរើការងារលើការបោះពុម្ព | **សិប្បកម្មតាមផ្ទះ**<br>- គ្រួសារចំនួន ៤៥គ្រួសារ ក្នុងមានថ្មី០៤គ្រួសារ បានចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ១៦៤នាក់(ស្រី ៧០នាក់) បានទទួលផលពីគម្រោងនេះ។<br>- គ្រួសារចំនួន ០៩គ្រួសារបានបំរើការងារលើការបោះពុម្ពចាប់ ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- យុវវ័យចំនួន ០១នាក់ បានចូលរៀនបោះពុម្ព |
| | **ក្រុមអាជីវកម្មខ្នាតតូច**<br>- កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ២០(រួមបញ្ចូល០៦គ្រួសារ ថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូល របស់ពួកគេ ដោយមាន | **ក្រុមអាជីវកម្មខ្នាតតូច**<br>- កំពុងផ្តល់ការបណ្តុះបណ្តាល ២០គ្រួសារ ក្នុងនោះមានថ្មី៧គ្រួសារដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារ ៧៦នាក់ (ស្រី៣០នាក់) |

| | | |
|---|---|---|
| | កុមារចំនួន ៦៤នាក់ដែលនឹងទទួលបានផលពីអាជីវកម្មក្នុង១ឆ្នាំ | បានទទួលផលពីអាជីវកម្មនេះ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- គំរោងនេះបានកែលំអរចនាសម្ព័ន្ធការងារ និងចាប់អនុវត្តរចនាថ្មីនៅខែ មិថុនា ឆ្នាំ២០១៣ ។<br>- មិត្តអប់រំមិត្តចំនួន ០២នាក់(ស្រី០១នាក់) បានចូលរួមប្រជុំស្តីពីដំណោះស្រាយប្រចាំខែគ្រប់អង្គការទាំងអស់នៅសង្កាត់គោករការ នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ។<br>- យុវវ័យចំនួន ១២ (ស្រី ០៨៩នាក់ និងបុគ្គលិកមិត្តសំឡាញ់ចំនួន ០៣ (ស្រី ០១នាក់) បានចូលរួមធ្វើយុទ្ធនាការអនាម័យនៅសហគមន៍អណ្តូង ដែលរៀបចំដោយអង្គការដៃនដី នាថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៣ ។<br>- បានរៀបចំយុវវ័យចំនួន ០៣(ស្រី ០១នាក់) ចូលរួមសិក្ខាសាលាស្តីពី នៃការចូលរួមរបស់យុវវ័យក្នុងការអភិវឌ្ឍន៍ ឃុំ សង្កាត់ នៅអង្គការ SCAP នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៣<br>- បានរៀបចំយុវជនចំនួន ០១នាក់ ចូលរួមសិក្ខាសាលាស្តីពីទិវាអ្នកស្ម័គ្រចិត្ត នៅកម្ពុជា នៅវិទ្យាស្ថានអប់រំ នាថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៣ ។<br>- យុវវ័យចំនួន ៣៤(ស្រី១៣នាក់) បានចូលរួមប្រជុំស្តីពីការបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់ប្រជាការពារស្ត្រី និងកុមារ នៅមណ្ឌលយុវវ័យខ្ញុំ និងអ្នក នាថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៣ ។ |
| **៤.៣ មណ្ឌលស្នាក់នៅបណ្តោះអាសន្ន** | - **មណ្ឌលស្នាក់នៅបណ្តោះអាសន្ន**ចំនួន ៣ កំពុងផ្តល់កន្លែងស្នាក់នៅដ៏មានសុវត្ថិភាពដល់កុមារ/យុវវ័យ ជាអតិបរមារហូតដល់ ៥០០នាក់ ក្នុងមួយឆ្នាំ<br>- សេវាចំនួន ២៤,០០០ នៃសកម្មភាពកម្សាន្ត ទស្សនកិច្ច ការចូលរួមរបស់កុមារ ការសួរសុខទុក្ខ ការការពារកុមារ បានផ្តល់ដល់កុមារ/យុវវ័យ នៅក្នុងមណ្ឌលទាំងអស់ក្នុងនោះមានសេវាព្យាបាលចំនួន ៩,០០០ ដង<br>- កុមារ/យុវវ័យចំនួន ៣៥០នាក់ មកពីតាមផ្លូវ និងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន | **មណ្ឌលស្នាក់នៅបណ្តោះអាសន្ន** ជាកន្លែងស្នាក់នៅបណ្តោះអាសន្ន ប្រកបដោយសុវត្ថិភាពសម្រាប់កុមារ និងយុវវ័យ កំឡុងពេលសិក្សារបស់ពួកគេ។<br>- មណ្ឌលស្នាក់នៅបណ្តោះអាសន្នចំនួន ៣ កំពុងផ្តល់កន្លែងស្នាក់នៅដ៏មានសុវត្ថិភាពដល់កុមារ/យុវវ័យ ៤៨០នាក់(ស្រី១៣៣នាក់) ក្នុងនោះមានថ្មី៨៩នាក់(ស្រី២៦នាក់) ក្នុងត្រីមាសនេះ ដែលមានទីតាំងក្នុងសង្កាត់ទឹកល្អក់ទី៣ សង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃ១ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ |

| | | |
|---|---|---|
| | និងបាន ចូលរួមសកម្មភាពនៅជុំរុំសប្បាយនៅខេត្តកំពង់ស្ពឺ ក្នុងមួយឆ្នាំ<br>- ការចូលរួមរបស់កុមារត្រូវបានធានាយ៉ាងជាក់ច្បាស់តាមរយៈការប្រជុំទូទៅជាទៀងរាល់សប្តាហ៍តាមការបោះឆ្នោត និងតាមប្រអប់សំបុត្រសំណើរដែលមាននៅតាមមណ្ឌលស្នាក់នៅបណ្តោះអាសន្នទាំងអស់ | - សេវាចំនួន ២១,៣៤០(ស្រី ៣,១៤៨នាក់) នៃសកម្មភាពកម្សាន្ត ទស្សនកិច្ច ការចូលរួមរបស់ កុមារ ការសួរសុខទុក្ខ ការការពារកុមារបានផ្តល់ដល់ កុមារ/យុវវ័យនៅក្នុងមណ្ឌល ទាំងអស់ក្នុងនោះមានសេវាព្យាបាលចំនួន ៨,៤១៤( ស្រី ៧១៨នាក់) ដង ។<br>- កុមារ/យុវវ័យមកពីតាមផ្ទះ និងមណ្ឌលស្នាក់នៅបណ្តោះអាសន្នចំនួន២១៥នាក់ (ស្រី ៥៥នាក់) បានចូលរួម សកម្មភាព នៅជុំរុំសប្បាយសប្បាយ ខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យបានចូលរួមការប្រជុំទូទៅ ជាទៀងរាល់សប្តាហ៍ និងបើកប្រអប់សំបុត្រសំណើរចំនួន ២ដងក្នុងមួយខែ នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នទាំងអស់ ក្រោយពីបានប្រជុំ និងបើកប្រអប់សំបុត្ររួចពុំមានករណី ឬសំណើរសុំពិសេសឡើយ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- កុមារ/យុវវ័យចំនួន ៥៨៨នាក់ (ស្រី ១៧៤នាក់) បានដឹកនាំទៅលេងរមណីយដ្ឋានភ្នំតាម៉ៅ ភ្នំបាសិត និង ភ្នំឧដុង្គ ។<br>- បានដឹកនាំកុមារ/យុវវ័យចំនួន ៣០នាក់ (ស្រី ១០នាក់) ទៅវត្តមហាមន្ត្រី និងវត្តទួល ទំពូង កំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០១៣<br>- បានដឹកនាំក្រុមណាកូទិចអាណាមិក Narcotics Anonymous ចំនួន ៣៤នាក់ (ស្រី ០៧នាក់) ទៅលេងវ៉ាតធើផាកនៅថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០១៣<br>- បានបញ្ជូនយុវវ័យចំនួន ២៧នាក់ (ស្រី ០៧នាក់) បានទៅចូលរួមបោះឆ្នោតថ្នាក់ជាតិ នៅខេត្តរបស់ពួកគេ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៣ ។<br>- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៥៣ និង ៥៤របស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី ១ នៅសាលារាជធានីភ្នំពេញស្តីពីរបាយការណ៍រីកចំរើនប្រចាំខែតុលា និងវិច្ឆិកា និងផែនការសម្រាប់ត្រីមាសបន្ទាប់ ។ |

| | | |
|---|---|---|
| ៤.៤ កម្មវិធីអប់រំ | **មជ្ឈមណ្ឌលអប់រំ:**<br>- មជ្ឈមណ្ឌលអប់រំ កំពុងផ្តល់ការអប់រំបំប៉នក៏រិតបឋមសិក្សាដល់កុមារ ២០០ នាក់ក្នុងមួយឆ្នាំ<br>- ត្រៀមរៀបចំធ្វើសមាហរណកម្មកុមារចំនួន ៥០០ នាក់ទៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- នឹងរៀបចំការប្រជុំជាមួយមាតាបិតា ៤លើក ដើម្បីត្រៀមធ្វើការបញ្ចូលទៅក្នុងសាលារដ្ឋ ក្នុងមួយឆ្នាំ<br>- កុមារចំនួន ១,៥០០នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន ៥០នាក់ នឹងបានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ | - **មជ្ឈមណ្ឌលអប់រំ** ផ្តល់សកម្មភាពអប់រំបំប៉នក៏រិតបឋមសិក្សាដើម្បីសម្របសម្រួលលើការសមាហរណកម្មសិស្សទៅសាសារដ្ឋ និងផ្តល់ការអប់រំជាមូលដ្ឋានដល់កុមារដែលរស់នៅ និងធ្វើការតាមផ្លូវ/សហគមន៍។<br>- មជ្ឈមណ្ឌលអប់រំបានផ្តល់ការអប់រំបំប៉នក៏រិតបឋមសិក្សាដល់កុមារ ៣១០នាក់ (ស្រី ១២៦នាក់) នៅមជ្ឈមណ្ឌលអប់រំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កិច្ចប្រជុំចំនួន ៣លើកបានរៀបចំក្នុងឆ្នាំនេះ រួមមាន:<br>  - បានរៀបចំប្រជុំមាតាបិតាសិស្សចំនួន ៨១នាក់ (ស្រី៦៥នាក់)ដើម្បីជ្រើសរើស តំណាងមាតាបិតាសម្រាប់ឆ្នាំ២០១៣ នៅក្លឹបប្រេន្ស នាថ្ងៃទី១៨ ខែមករាឆ្នាំ ២០១៣។<br>  - បានរៀបចំប្រជុំជាមួយនាយកសាលានិងតំណាងមាតាបិតាចំនួន ២៩នាក់ (ស្រី១៨ នាក់) ដើម្បីធ្វើបទបង្ហាញស្តីពីសេវាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងចំណាប់ អារម្មណ៍របស់នាយកសាលាពីកុមារមិត្តសំឡាញ់ដែលកំពុងសិក្សានៅសាលារដ្ឋនៅ ក្លឹបប្រេន្ស នាថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៣។<br>  - បានរៀបចំប្រជុំមាតាបិតាសិស្សចំនួន ១១៥នាក់ (ស្រី៩៤នាក់)ស្តីពីការធ្វើ សមាហរណកម្មសិស្សទៅសាលារដ្ឋ និងចែកចាយព័ត៌មានអំពីលទ្ធផលការសិក្សាពួកគេ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៣ នៅក្លឹបប្រេន្ស។<br>- កុមារចំនួន ១,៥៨៤នាក់ (ស្រី៦៨២នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋនៅរាជធានីភ្នំពេញ រួមបញ្ចូល១៣២ (ស្រី៥១នាក់) បានធ្វើយុទ្ធនាការ និងកុមារចំនួន ២៩៧ (ស្រី ១២១នាក់) ដែលគ្រួសារ របស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឱ្យរៀននៅសាលារដ្ឋ។<br>- កុមារចំនួន៣២៨នាក់ (ស្រី១៥០នាក់) បានគាំទ្រ និងសមាហរណកម្ម ទៅសាលារដ្ឋ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ |

| | | |
|---|---|---|
| | | - កុមារចំនួន៦៨នាក់ (ស្រី២៧នាក់) បានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- មិត្តសំឡាញ់បានទទួលល្បែងបង្កើនប្រាជ្ញាពី LEGO តាមរយៈម្ចាស់ មូលនិធិវិហារ ដាណឺមាក ព្រមទាំងបានចែកចាយដល់សាលារដ្ឋចំនួន៣៧ សាលា និងអង្គការដៃគូចំនួន០៨ ក្រោមអធិបតីភាពរបស់ ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមប្រជុំសន្និបាតស្តីពីការអប់រំឆ្នាំ២០១២ នៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញនាថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៣។<br>- បុគ្គលិកមកពីអង្គការហ្វាព្នឺសិល្បៈចំនួន ០១នាក់ បានមកទស្សនកិច្ចសិក្សាស្តីពីការអប់រំក្រៅប្រព័ន្ធនៅមជ្ឈមណ្ឌលអប់រំ នាថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៣។<br>- បានចូលរួមប្រជុំរបាយការណ៍ស្តីពីការស្ទង់មតិនៃការអប់រំក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជា នៅអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៣។<br>- យុវវ័យស្ម័គ្រចិត្តមកពីអង្គការស៊ីប៉ាចំនួន ២០ (ស្រី១០នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពីឧបករណ៍សិក្សា នៅក្លឹបប្រេៀន្យ នាថ្ងៃទី ២៨ -២៩ ខែ មីនា ឆ្នាំ២០១៣។<br>- បានធ្វើពិធីចែកសម្ភារៈសិក្សាដល់កុមារដែលត្រូវបន្តការសិក្សានៅសាលារដ្ឋមានការចូលរួមជាអធិបតី ដោយអនុប្រធានមន្ទីរសង្គមកិច្ចអតីតយុវជនយុវនីតិសម្បទា និងប្រធាន ការិយាល័យមបបនៃមន្ទីរអប់រំនិងកីឡារាជធានីភ្នំពេញនៅក្លឹបប្រេៀន្យ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ។<br>- កុមារចំនួន ១៩ (ស្រី១០នាក់) បានចូលរួមធ្វើតេស៍អាហារូបករណ៍នៅសាលាអន្តរជាតិ Kent Ridge នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ។ |

| | | |
|---|---|---|
| | | - បានចូលរួមប្រជុំស្តីពីការរៀបចំអនុវត្តន៍ផែនការឆ្នាំ ២០១៤ នៅក្រសួងអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។ |
| | **មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ** (ថ្នាក់ជំនាញ និងអាជីវកម្ម) កំពុងផ្តល់ជំនាញវិជ្ជាជីវៈផ្សេងៗគ្នា ដល់កុមារចំនួន ៦00នាក់ ក្នុងមួយឆ្នាំ និងជួយពួកគេឱ្យមានការងារធ្វើ (ដោយមានយុវវ័យជាស្រីចំនួន ៣0%)នឹងផ្តល់ គាំទ្រពួកគេដើម្បីសមាហរណកម្ម ទៅធ្វើការ និងបង្កើតអាជីវកម្មខ្នាតតូច<br>- យុវវ័យចំនួន ១២0នាក់ នឹងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់មួយក៏រិតពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្នុង១ ឆ្នាំ<br>- នឹងផ្តល់សេវាអប់រំក្រៅប្រព័ន្ធដល់យុវវ័យ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១៥0,000 ដង ( បំណិនជីវិត កុំព្យូទ័រ ការព្យាបាល និងអក្សរសាស្ត្រ) ។<br>- នៅឆ្នាំ២០១៧ អត្រានៃការបោះបង់ការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមានការថយមកត្រឹម ១0% (ផ្អែកលើរបាយការណ៍ឆ្នាំ ២០១២=១៨%)*<br>- យុវវ័យ ចំនួន ២0នាក់ បានគាំទ្រឱ្យរស់នៅឯករាជ្យជាក្រុម កំឡុងពេលសិក្សារបស់ពួកគេនៅអង្គការមិត្តសំឡាញ់<br>- យុវវ័យ ១២0នាក់ នឹងទទួលបានជួយស្វែងរកការងារឱ្យធ្វើបង្កើតរបរដោយខ្លួនឯង ក្នុងនោះមានយុវវ័យចំនួន ៣0នាក់ នឹងគាំទ្រឱ្យរកស៊ីដោយខ្លួនឯង និងរស់នៅឯក | **មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>ផ្តល់ការបណ្តុះបណ្តាលដ៏មានគុណភាពនាំមុខគេលើជំរើសការងារដ៏បិតថេរសម្រាប់យុវវ័យ ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ អង្គការមិត្តសំឡាញ់មាន 0៨ ជំនាញផ្សេងៗគ្នា ។<br>- បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗគ្នាដល់យុវវ័យចំនួន៥៣៤នាក់( ស្រី ១៣១នាក់) ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- មានយុវវ័យចំនួន ១0៧នាក់( ស្រី២១នាក់) បានមកទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់កំរិតទីមួយពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- សេវាអប់រំចំនួន ១៥៣,៧៤៨ ( ស្រី៤៧,៥៥៩ដង) រួមមាន ( បំណិនជីវិត កុំព្យូទ័រ ការព្យាបាល ការដាក់ការងារ និងអក្សរសាស្ត្រ) បានផ្តល់ដល់យុវវ័យនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>- យុវវ័យចំនួន ៥២នាក់ (ស្រី១៩នាក់) ស្មើនឹង ១0 % បានបោះបង់ចោលការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ហើយមិនបានត្រឡប់មកចូលរៀនវិញនៅក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ ។<br>- បានគាំទ្រយុវវ័យចំនួន ១៤នាក់ (ស្រី 0៦នាក់) ឱ្យរស់នៅឯករាជ្យជាក្រុមកំឡុងពេលសិក្សានៅអង្គការមិត្តសំឡាញ់ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- បានជួយស្វែងរកការងារឱ្យធ្វើ របង្កើតមុខរបរដោយខ្លួនឯងដល់ និងរកការងារដោយខ្លួនឯង យុវវ័យចំនួន ៩៤នាក់ (ស្រី១៧នាក់) ក្នុងនោះយុវវ័យចំនួន ៥៩នាក់( ស្រី0៨) បានគាំទ្ររស់នៅឯករាជ្យនៅរាជ ធានីភ្នំពេញចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។ |

| | | |
|---|---|---|
| | រាជ្យនៅភ្នំពេញក្នុងមួយឆ្នាំ<br>- បន្ទាប់ពីការធ្វើសមាហរណកម្មរយៈពេល ៦ខែ នឹងមានយុវវ័យ ៨០ % កំពុងបំរើការងារ ឬប្រកបរបរដោយខ្លួនឯង<br>- ១០០% នៃជំនាញវិជ្ជាជីវៈទាំង៩ ក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបង្កើនប្រាក់ចំណូល<br>- បណ្តុះបណ្តាលអាជីវកម្មជំនាញវិជ្ជាជីវៈនឹងទទួលបានប្រាក់ចំណូលចំនួន ៥៥,០០០ ដុល្លារក្នុងឆ្នាំ២០១៣ បង្កើន១០% រៀងរាល់ឆ្នាំ<br>- ភោជនីយដ្ឋានចំនួន៣ នឹងបង្កើនប្រាក់ចំណូល១,២៦៤,០៩១ដុល្លារ ជាមួយប្រាក់ចំណេញ ២៦០,៩០៧ នាក់ ក្នុង១ឆ្នាំ<br>**ភោជនីយដ្ឋានហ្រ្វេន្ទ:**៦៣៩,៣៤៥ដុល្លារ ) ប្រាក់ចំណេញៈ ១៤៥,១០៣ ដុល្លារ<br>**ភោជនីយដ្ឋានរំដេងៈ**៥៦៩,៧៦០ដុល្លារ ប្រាក់ចំណេញ ៧៥,០៤១ ដុល្លារ<br>**កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ៥៤,៩៨៥ដុល្លារ និងចំណេញ ៥,០០០ដុល្លារ ។<br>- **កន្លែងធ្វើក្រចក** ស្ថិតនៅខាងក្នុង ហាងហ្វ្រេន្ទអេនស្តាស់ នៅលើផ្លូវ ១៣ ជិត ភោជនីដ្ឋានហ្វ្រេន្ទ ៥៤,៩៨៥ដុល្លារ ប្រាក់ចំណេញ ៤០,៣៥៨ ដុល្លារ | - បន្ទាប់ពីការធ្វើសមាហរណកម្មរយៈពេល ៦ខែមានយុវវ័យ ៩០% កំពុងបន្ត បំរើការងារ ឬប្រកបរបរដោយខ្លួនឯង ។<br>- ១០០% នៃជំនាញទាំង ៨ របស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ អាចបង្កើនប្រាក់ចំណូលក្នុងឆាំនេះ ។<br>- ប្រាក់ចំណូលចំនួន ៤៧,៣៨៤.៤៦ដុល្លារបានមកពីអាជីវកម្មបណ្តុះបណ្តាលវិជ្ជាជីវៈទាំង ៨ ជំនាញ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អង្គការមិត្តសំឡាញ់ ក្នុងឆ្នាំនេះ ។<br>- ភោជនីយដ្ឋានចំនួន៣ បានបង្កើនប្រាក់ចំណូល ១,២៥២,៩៥៦.២៤ដុល្លារ និងចំណេញចំនួន ១៧២,៤១១.៦៧ដុល្លារ ក្នុងឆ្នាំនេះ ។<br>- **ភោជនីយដ្ឋានហ្វ្រេន្ទ:**៦៨២,៥៤២.៤៨ដុល្លារ ប្រាក់ចំណូល និងចំណេញ ១២៤,១០៤.៣៥ ដុល្លារ<br>- **ភោជនីយដ្ឋានរំដេងៈ**៥៣៣,១៣០.៥៧ដុល្លារ ប្រាក់ចំណូល និងចំណេញ ៤៨,៥៤១.២៤ ដុល្លារ ។<br>**កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន៣៧,២៨៣.១៩ដុល្លារ និងខាត ២៣៣.៩៦ ដុល្លារ ។ (កាហ្វេមិត្តសំឡាញ់ បានបិទនៅចុងខែសីហា ២០១៣ នេះ)<br>- **កន្លែងធ្វើក្រចក**បង្កើតបានប្រាក់ចំណូលចំនួន ១៣,៣៧៤.០០ដុល្លារ និងចំនួន ២,៩៨៩.៧០ ដុល្លារ ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- ថ្នាក់អេឡិចត្រូនិចបានបិទនៅខែសីហា ឆ្នាំ២០១៣ ។<br>- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការផ្សព្វផ្សាយសេវារបស់មណ្ឌលដោយធ្វើបទបង្ហាញជូនដល់ សមាជិកសុវត្ថិភាពកុមារចំនួន ១២នាក់, នាយកសាលាចំនួន ២៩នាក់, តំណាងមាតាបិតាសិស្សចំនួន ២០នាក់ បុគ្គលិក៥១នាក់មកពី២៧អង្គការ( ឧទាហរណ៍ |

| | | |
|---|---|---|
| | | អង្គការគ្រួសាថ្មី, Global Development Group partners, និង Skateistan) ដោយមានចំនួន៥ដងដាច់ដោយឡែកពីគ្នា ដែលជាលទ្ធផល នាយកសាលាបានបញ្ជូនយុវវ័យចំនួន ១៦នាក់(ស្រី០៣នាក់) មករៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>- បានចូលរួមស្តាប់បាយការណ៍របស់យូណេស្កូ ស្តីពីការត្រួតពិនិត្យរបាយការណ៍ លើយុវវ័យ និង ជំនាញ ឆ្នាំ២០១២ នៅសណ្ឋាគារ Raffles Hotel Le Royal នាថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៣ ។<br>- បានចូលរួមប្រជុំស្តីពីរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំសម្រាប់អង្គការសង្គ្រោះកុមារ នៅការិយាល័យអង្គការសង្គ្រោះកុមារនាថ្ងៃទី ១០-១១ ខែមេសា ឆ្នាំ២០១៣ ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍កម្ពុជាផ្នែកគេហកិច្ចតាមស្តង់ដារអាស៊ាន នៅអង្គការភាពញញឹមនៃកុមារ នាថ្ងៃទី ២០-២៦ ខែឧសភា ឆ្នាំ២០១៣ ។<br>- កុមារចំនួន ០៩នាក់ ( ស្រី ០៣នាក់) បានចូលរួមទិវាពលកម្មអន្តរជាតិនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា នាថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៣ ។<br>- រៀបចំសិស្សចំនួន ០៦(ស្រី០៣នាក់) បានចូលរួមសម្ភាសន៍ស្តីពីទិវាសន្តិភាពអន្តរជាតិ ដែលធ្វើដោយអង្គការយូនីសេសន៍នៅអង្គការមិត្តសំឡាញ់ នាថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៣ ។<br>- បុគ្គលិកចំនួន ៤១(ស្រី ១៧នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីស្តីអំពីការលក់ និងសេវាឧត្តមភាពនៃជំសណ្ឋារកិច្ចវិជ្ជាជីវៈ និងរបៀបប្រើប្រាស់វិធីសាស្ត្រច្នៃប្រឌិត ឧបករណ៍ និងហ្គេម នៅប្រូឡូអ៊ីនធឺសិនណេល ដែលគាំទ្រដោយ នាខែកញ្ញា និងតុលា ឆ្នាំ២០១៣<br>- បានចូលរួមប្រជុំស្តីពីសមិទ្ធផល និងផែនការយុទ្ធសាស្ត្រសំរាប់រយៈពេល ៣ឆ្នាំ នៅភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។<br>- បានចូលរួមក្នុងវេទិកាពិភាក្សាស្តីពីការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាកម្មវិធីសេដ្ឋ |

| | | |
|---|---|---|
| | | កិច្ចនៅក្នុងប្រទេសកម្ពុជា នៅសណ្ឋាគា ប៊ុម៉ារ៉ា នាថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។ |
| | - **ក្លឹបហ្វ្រេនៈ**កំពុងផ្តល់សេវាសកម្មភាពផ្នែកវប្បធម៌ផ្សេងៗ ចំនួន ១០០,០០០ រួមមាន បណ្ណាល័យ រាំ កីឡា ល្ខោន គំនូរ ទស្សនកិច្ចសិក្សា និងព្រឹត្តិការណ៍ពិសេស ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងមួយឆ្នាំ<br>- ក្លឹបហ្វ្រេនរឹងបើកសម្រាប់កុមារ/យុវវ័យនៅតាមផ្លូវ និងសហគមន៍ចំនួន ២ ដង ក្នុងមួយ សប្តាហ៍ ដើម្បីផ្តល់សេវាបំណិនជីវិតចំនួន ៥,០០០ដង ដល់ពួកគេ | **ក្លឹបហ្វ្រេនៈ**ជាមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់ ដែលកុមារ/យុវវ័យអាចអនុវត្តសកម្មភាពកម្សាន្តសប្បាយ និងវប្បធម៌ រួមមាន កីឡា គំនូរ ផាត់ពណ៌ បណ្ណាល័យ រាំ និងតន្ត្រី ។<br>- ក្លឹបហ្វ្រេនបានផ្តល់សេវាផ្នែកវប្បធម៌ទាំងក្នុង និងក្រៅមណ្ឌលចំនួន ១២០,៦១៥ ដង (ស្រី៣៨,២៦៥ ដង )សេវាទាំងនោះរួមមាន បណ្ណាល័យ រាំ កីឡា ល្ខោន គំនូរ ទស្សនកិច្ចសិក្សា និងព្រឹត្តិការណ៍ពិសេស ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងកុមារនៅតាមផ្លូវ ។<br>- ក្លឹបហ្វ្រេន បានបើកសម្រាប់កុមារ/យុវវ័យមកពីតាមផ្លូវ និងសហគមន៍ចំនួន ២ដង ក្នុងមួយសប្តាហ៍ ដោយផ្តល់សេវាបំណិនជីវិតចំនួន ១៩,៣៣៤ដង ( ស្រី៤,៨៧០ដង) ដល់ពួកគេ ។<br><br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេសៈ**<br>- សេវាចំនួន ១,៤៥៧ (ស្រី៣០៣)ដង នៃកុមារ/យុវវ័យ បានចូលរួមការប្រកួតកីឡានៅខាងក្រៅ រួមមានទ្រីយ៉ាថ្លុង កីឡាបាល់បោះ បាល់ទាត់ ប៉េងប៉ុង ហែលទឹក និង បាល់អោប ។ ជាលទ្ធផលទទួលបានជ័យលាភីមេដាយមាស២ សម្រាប់ការប្រកួត បាល់ទាត់មេដាយប្រាក់១សម្រាប់ទ្រីយ៉ាថ្លុង និងទឹកប្រាក់ចំនួន ២០០,០០០រៀល ។<br>- កុមារ/យុវវ័យចំនួន ២៩៨នាក់ (ស្រី១៣៤នាក់) បានចូលរួមការប្រកួតកីឡានៅខាងក្នុង រួមមាន កីឡាបាល់ទាត់ បាល់បោះ និង បាល់អោប ។<br>- បានរៀបចំសម្តែងប្រចាំត្រីមាសចំនួន២ដងដែលមាន កុមារ/យុវវ័យចំនួន ៩៨នាក់ (ស្រី ៦០នាក់) បានចូលរួមសម្តែង និងមានអ្នកទស្សនាចំនួន ៤៣០ នាក់ចូលរួម នៅក្លឹបហ្វ្រេន ។ |

| | | |
|---|---|---|
| | | - កុមារចំនួន ៩៥ នាក់(ស្រី ៣៦នាក់) បានចូលរួមទស្សនាការតាំងពិពណ៌គំនូររូបភាព និងអានសៀវភៅរឿង នៅវិទ្យាស្ថានបារាំងនៅកម្ពុជា ។<br>- កុមារ/យុវវ័យចំនួន ៤០ នាក់(ស្រី ១១នាក់) បានចូលរួមទស្សនាការតាំងពិពណ៌ ស្តីពីវប្បធម៌អាស៊ាននៃកម្ពុជា នៅសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ នាថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យចំនួន ៣០ នាក់(ស្រី ០៥នាក់) បានចូលរួមសិក្ខាសាលាស្តីពីភ្លេង ពិណពាទ្យ ក្លឹបប្រេនឡូ នាថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៣។<br>- កុមារ/យុវវ័យចំនួន ៤១នាក់ (ស្រី ២៤នាក់) បានចូលរួមសំម្តែង ដើម្បីអបអរសាទរខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ នៅក្រោមប្រធានបទ "អភិវឌ្ឍន៍កុមារជាគ្រឹះនៃការអភិវឌ្ឍន៍ជាតិ" ដែលមានអ្នកចូលទស្សនាចំនួន ៤៥០ នាក់ចូលរួម នៅក្លឹបប្រេនឡូ នាថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣។<br>- កុមារ/យុវវ័យចំនួន ៦០នាក់ (ស្រី២៨នាក់) បានចូលរួមទស្សនាខ្សែភាពយន្ត បេតិកភណ្ឌអន្តរជាតិ នៅសាលមហោស្រពចតុមុខ នាថ្ងៃទី០៥/០៧ ខែមិថុនា ឆ្នាំ២០១៣។<br>- កុមារ/យុវវ័យចំនួន ១៩៣ នាក់(ស្រី ៩៧នាក់) បានចូលរួមគូរគំនូរនៅជញ្ជាំងជាមួយក្រុមនិស្សិតសូតា មកពីប្រទេសសិង្ហបុរី នៅក្លឹបប្រេនឡូ។<br>- កុមារចំនួន ១០នាក់(ស្រី ០១នាក់) បានចូលរួមការប្រកួតគូរគំនូរ នៅសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធកុមារ នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣។<br>- កុមារ/យុវវ័យចំនួន ១៣១នាក់ (ស្រី៤៣នាក់) បានចូលរួមទស្សនាព្រះបរមរាជវាំង និងមជ្ឈមណ្ឌលបូផាណា។<br>- កុមារចំនួន ៣៥នាក់(ស្រី ០៩នាក់) បានចូលរួមពង្រាងគូរគំនូរនៅលើជញ្ជាំងរបងមិត្តសំឡាញ់ ។ |

| | | |
|---|---|---|
| | | - កុមារចំនួន ៤២នាក់(ស្រី ១៣នាក់) បានចូលរួមផាត់ពណ៌គូរគំនូរនៅលើជញ្ជាំងរបងមណ្ឌលអប់រំ ។<br>- បានរៀបចំកុមារ/យុវវ័យចំនួន២៧ នាក់(ស្រី ២០នាក់) បានចូលរួមសិក្ខាសាលា ស្តីពីសិល្បៈ នៅក្លិបប្រេន្ទ្យ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣<br>- បានរៀបចំកុមារ/យុវវ័យចំនួន ៣០នាក់(ស្រី ១៨នាក់) បានចូលរួមសិក្ខាសាលា ស្តីពីចំរៀងឯក នៅក្លិបប្រេន្ទ្យ នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣<br>- បានរៀបចំកុមារ/យុវវ័យចំនួន០៧នាក់ បានចូលសិក្ខាសាលា ស្តីពី ការ៉ាតេដូ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ។<br>- បានរៀបចំកុមារ/យុវវ័យចំនួន ៣៧ (ស្រី១៥នាក់) បានចូលរួមតាំងពិពណ៌ ស្តីពីការប្រកួតប្រជែងរូបថត ដងទន្លេមេគង្គ នៅ សហភាពអ៊ឺរ៉ុប នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។<br>- បានរៀបចំកុមារ/យុវវ័យចំនួន ០៤ ( ស្រី ០២នាក់) បានចូលរួមថតវីឌីអូ ស្តីពីការអប់រំដែលរៀបចំដោយអង្គការប្រេន្ទ្យអ៊ិនធឺណាសិនណល នាថ្ងៃទី ២៣-២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។<br>- បានរៀបចំកុមារ/យុវវ័យចំនួន ៣០ (ស្រី ០៨នាក់) បានចូលរួមរាំសំដែងនៅទូរទស្សន៍អាស៊ីអគ្នេយ៍នាថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ ។<br>- អាគារក្លឹបប្រេន្ទ្យត្រូវបានខូចខាតដោយសារភ្លៀងធ្លាក់ខ្លាំង ហើយសកម្មភាពនៅក្លិបប្រេន្ទ្យបានប្តូរទៅនៅមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធនាថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៣ ។<br>- បានរៀបចំកុមារ/យុវវ័យចំនួន ៦៥ ( ស្រី ៣៤នាក់) បានចូលរួមសំដែងក្នុងកម្មវិធីទិវាអេដស៍ពិភពលោក នៅអង្គការមិត្តសំឡាញ់ដែលមានអ្នកទស្សនាចំនួន ៨០០នាក់ នាថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៣ ។ |
| **៤.៥ ក្រុមសមាហរណកម្ម** ផ្តល់ការគាំទ្រ ដល់កុមារ | **សមាហរណកម្ម:** | **សមាហរណកម្ម:** |

| | | |
|---|---|---|
| ២០០ នាក់ក្នុងមួយ ឆ្នាំ ដើម្បីសមាហរណកម្ម ទៅកាន់គ្រួសារ (គ្រួសារបង្កើត គ្រួសារសាច់ញាតិ និងគ្រួសារធម៌) នៅតាមបណ្តាខេត្តនានា។ | - អាណាព្យាបាលនៅខេត្ត ចំនួន ៣៥០ នាក់នឹងទទួលបានសេវារួមមានបំណិនជីវិត ការគាំទ្រឯកសារផ្លូវច្បាប់ និងការបញ្ជូន<br>- នឹងរៀនចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ ចំនួន ៤ ដងក្នុង១ ឆ្នាំ<br>- កុមារចំនួន ១២០ នាក់ បានគាំទ្រលើការសមាហរណកម្មគ្រួសាររបស់ពួកគេ (រួមបញ្ចូលគ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ )ឬរស់នៅឯករាជ្យនៅក្នុង ខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- កុមារចំនួន២០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅកាន់គ្រួសារធមិក្នុង១ឆ្នាំ<br>- កុមារចំនួន ៨០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅសាលារដ្ឋក្នុងខេត្តរបស់គេក្នុង១ឆ្នាំ<br>- កុមារចំនួន ៣៥០ នាក់ នៅសាលារដ្ឋ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ | - អាណាព្យាបាលនៅខេត្ត ចំនួន ២២៥នាក់ (ស្រី ១៤៩នាក់) បានទទួល សេវារួមមាន បំណិនជីវិតការគាំទ្រឯកសារផ្លូវច្បាប់ និងការបញ្ជូន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កុមារ/យុវវ័យចំនួននៅខេត្ត ចំនួន ៤៧០នាក់ (ស្រី ២១៦នាក់) បានទទួលសេវារួមមាន បំណិនជីវិត ស្វែងរកនិង ប៉ាន់ប្រមាណ គ្រួសារ សួរសុខទុក្ខ ការគាំទ្រឯកសារផ្លូវច្បាប់ និងការបញ្ជូន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កិច្ចប្រជុំចំនួន ៤លើកបានរៀបចំក្នុងឆ្នាំនេះ ស្តីពី លក្ខខណ្ឌនៃគណៈកម្មាធិ ការគ្រួសារធមិ និងដំណោះស្រាយសម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់ក្រុមការងារ និងការបង្កើតទម្រង់របាយការណ៍របស់ក្រសួង និង ធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌនៃគណៈកម្មាធិការគ្រួសារធមិរបស់ក្រសួង ។<br>- យុវវ័យចំនួន ៥៨នាក់ (ស្រី ២៥នាក់) បានគាំទ្រ លើការសមាហរណកម្មទៅកាន់គ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ និងរស់នៅឯករាជ្យ នៅក្នុងខេត្តរបស់ពួកគេ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កុមារាចំនួន ០៨នាក់ (ស្រី ០១នាក់) បានសមាហរណកម្មទៅកាន់គ្រួសារធមិរយៈពេលខ្លី នៅរាជធានី ភ្នំពេញ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កុមារថ្មីចំនួន ៧៤នាក់ (ស្រី៣៧នាក់) បានទទួលការ គាំទ្រសម្ភារៈសិក្សា និងសមាហរណកម្មទៅ បន្តការសិក្សានៅសាលារដ្ឋក្នុងខេត្តរបស់ពួក គេ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- កុមារចំនួន ២២២នាក់(ស្រី៩៧នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅ សាលារដ្ឋក្នុងខេត្តរបស់ពួកគេ ក្នុងនោះមានកុមារ ៣៨នាក់(ស្រី ២០នាក់) ដែលគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឱ្យរៀននៅសាលារដ្ឋ ។<br>- យុវវ័យចំនួន ១៥នាក់ (ស្រី០៤នាក់) បានជួយ ស្វែងរកការងារឱ្យធ្វើ និងបង្កើតមុខរបរ |

| | | |
|---|---|---|
| | - យុវវ័យចំនួន ៣០នាក់ នឹងជួយស្វែងរកការងារឱ្យធ្វើ រឺបង្កើតមុខរបរ ដោយខ្លួនឯង នៅខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- យុវវ័យចំនួន ៩០ នាក់នឹងត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១៥ គ្រួសារ នឹងទទួលបានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញក្នុង ១ឆ្នាំ<br>- គ្រួសារចំនួន១០ នឹងទទួលបានការបណ្តុះបណ្តាល និងគាំទ្រសម្រាប់អាជីវកម្មខ្នាតតូចនៅក្នុងខេត្តរបស់ពួកគេ ដោយមានកុមារចំនួន ៤០នាក់ដែលនឹងទទួលបានផលពីអាជីវកម្មនេះ ក្នុង១ឆ្នាំ<br>- កុមារ/យុវវ័យចំនួន ៥០នាក់ នឹងទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត នៅខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- បទដ្ឋាននៃនិតិវិធីលើសមាហរណកម្ម (SoPs)នឹងកែលំអ បកប្រែ និងដំណើការដោយក្រុមការងារនៅចុងឆ្នាំ ២០១៣<br>- កិច្ចសហការជាមួយរាជរដ្ឋាភិបាល និងអង្គការដៃគូនឹង ត្រូវបានចាប់ផ្តើមតាមរយៈការប្រជុំ និងការបណ្តុះបណ្តាល | ដោយខ្លួនឯងនៅ ខេត្តរបស់ពួកគេ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- យុវវ័យចំនួន ៦១នាក់ (ស្រី១១នាក់) ទទួលបានការតាមដាន និងសួរសុខទុក្ខលើការងារ ឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន នៅតាមខេត្តរបស់ពួកគេ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១៣គ្រួសារ ដែលមានកូន ២៥នាក់ (ស្រី១២នាក់) បានគាំទ្រឱ្យត្រឡប់ទៅរស់នៅស្រុកកំណើតពួកគេវិញ ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- គ្រួសារចំនួន ២៣គ្រួសារ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីអាជីវកម្មខ្នាតតូច និង០៨ គ្រួសារបានគាំទ្រចាប់ផ្តើមអាជីវកម្មខ្នាតតូចនៅខេត្ត ដែលមានកូនចំនួន ៣៨នាក់ (ស្រី១៣នាក់) បានទទួលបានផលពីអាជីវកម្មនេះ ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- យុវវ័យចំនួន ២១នាក់ (ស្រី០៥នាក់)ទទួលបាន គាំទ្រក្នុងការធ្វើអត្តសញ្ញាណប័ណ្ណនៅខេត្តរបស់ពួកគេ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។<br>- បទដ្ឋាននៃនិតិវិធីលើសមាហរណកម្មបានបញ្ចប់ហើយបានផ្ញើជូនទៅ ប្រេនឡអ៊ិនធីណាសិនណាលដើម្បីត្រួតពិនិត្យ ។<br>- ប្រធានគម្រោងសមាហរណកម្មបានចែករំលែកព័ត៌មានស្តីពីកម្មវិធីគ្រួសារធមិដល់បុគ្គលិកចំនួន ០៨នាក់ មកពីអង្គការ កាដូ មណ្ឌលពន្លឺអនាគតកុមារ ម្លប់តាប៉ាង កញ្ញាលមិត្ត និង ហ្វាពន្លឺសិល្បះ នៅមិត្តសំឡាញ់នាឆ្នាំនេះ។<br>- បន្តការសហការជាមួយមន្ត្រីសង្គមកិច្ចរាជធានី/ខេត្ត និងអង្គការដៃគូលើការងារសមាហរណកម្ម រួមមាន ការស្វែងរក ការប៉ាន់ប្រមាណ ផែនការគ្រួសារ សមាហរណ កម្ម និងការតាមដាននៅ ២៤ខេត្ត/ក្រុង។ |
| **៤.៦ ដោយមានការគាំ** | | |

| | | |
|---|---|---|
| **ទ្រពីគម្រោងធុរកិច្ចសង្គម(FSB), មិត្តសំឡាញ់មានចិរភាព៦០%** | **អង្គការមិត្តសំឡាញ់នឹងមាននិរន្តភាព និរន្តភាព:៦០% ពីគម្រោងធុរកិច្ចសង្គម**<br>**សិប្បកម្មតាមផ្ទះ**<br>- អាណាព្យាបាលចំនួន១០០(រួមបញ្ចូល២៥គ្រួសារថ្មី) នឹងចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣០០នាក់ បានទទួលផលពីគម្រោងនេះ ក្នុង១ឆ្នាំ ។<br>- ការលក់ផលិតផលពីសិប្បកម្មតាមផ្ទះក្នុងហាងលក់ទំនិញប្រេន្ទ្យ អេន ស្តាហ្វផ្លូវ១៣ ទូលទំពូង និងរំដេង ៣០៧,០០០ ដុល្លារ<br><br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ១៤០ (រួមបញ្ចូល២០គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារចំនួន ៥០០នាក់ដែលនឹងទទួលបានផលពីអាជីវកម្មនេះ<br><br>- **មជ្ឈមណ្ឌលផលិតកម្ម**អាណាព្យាបាលចំនួន២០នាក់នឹងទទួលបានគាំទ្រឱ្យមានការងារ តាមរយៈគម្រោងធុរៈកិច្ចសង្គម ( អណ្តូង និងប្រេន្ទ្យអ៊ិនធីណាសិនណល)<br><br>- **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបប្រេន្ទ្យ) នឹងអាចរកចំណូលបានចំនួន ៣៦,០០០ដុល្លារ ក្នុងមួយឆ្នាំ (កើនឡើង២% ) និងប្រាក់ចំណេញចំនួន ២៥,០០០ ក្នុងមួយឆ្នាំ | **អង្គការមិត្តសំឡាញ់មាននិរន្តភាព ៥៦% ពីគម្រោងធុរកិច្ចសង្គម**<br>**សិប្បកម្មតាមផ្ទះ**<br>- អាណាព្យាបាលចំនួន ១០០រួមបញ្ចូលថ្មី ៣០គ្រួសារបានចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣៣៩នាក់( ស្រី ១៥៧នាក់) បានទទួលផលពីគម្រោងនេះ ។<br>- ការលក់ផលិតផលសិប្បកម្មតាមផ្ទះ ក្នុងហាងលក់ទំនិញប្រេន្ទ្យអេនស្តាហ្វផ្លូវ១៣ ប្រេន្ទ្យអេនស្តាហទូលទំពូង ប្រេន្ទ្យអេនស្តាហរំដេងកំពុងបង្កើនប្រាក់ចំណូលបានចំនួន ៣៥០,៦៩៣.៤៤ដុល្លារ និងប្រាក់ចំណេញ ១៤២,៩៧០.០៧ ដុល្លារ ។<br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល ១៨៤គ្រួសារ រួមបញ្ចូលថ្មី៥៩គ្រួសារ ដើម្បីបង្កើតអាជីវកម្ម ផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមាន កុមារ ៦៧៩នាក់ ( ស្រី២៩៥ នាក់) បានទទួលផលពីអាជីវកម្មនេះ ។<br><br>- **មជ្ឈមណ្ឌលផលិតកម្ម** អាណាព្យាបាលចំនួន ១៣នាក់បានទទួលការគាំទ្រឱ្យមានការងារ នៅសហគមន៏អណ្តូង និង ប្រេន្ទ្យអ៊ិនធីណាសិនណល តាមរយៈគម្រោងធុរៈកិច្ចសង្គម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- **ផលិតផលមិត្តសំឡាញ់**( សៀវភៅមុខម្ហូបនិងរបៀបធ្វើ) អាចរកចំណូលបានចំនួន ៣២,៣៧៩.៨៦ ដុល្លារ និងប្រាក់ចំណេញចំនួន ៣២,៣៧៩.៧២ ដុល្លារ ។<br>**ព្រឹត្តិការណ៏ និងកំណត់សម្គាល់ពិសេសៈ**<br>- ក្រុមសិប្បកម្មតាមផ្ទះ បានបង្កើតផលិតផលថ្មីចំនួន ០៩មុខបន្ថែមទៀត នៅក្នុង ឆ្នាំនេះ ។<br>- ក្រុមសិប្បកម្មតាមផ្ទះ បានផ្គត់ផ្គង់ផលិតផលរួមមាន កាបូបដៃ៥០០ ក្រូណូ៣៥០០ និង កាបូប laptop ៣៥០០ សម្រាប់ការបញ្ជាទិញពីក្រុមហ៊ុន Lumieres du Monde ។<br>- ក្រុមសិប្បកម្មតាមផ្ទះ បានចូលរួមតាំងពិព័ណ៌ និងលក់ផលិតផល ក្នុងព្រឹត្តិការណ៏ចំនួន០៩ |

| | | |
|---|---|---|
| | | នៅសាលាអន្តរជាតិភ្នំពេញ៣ដង មេតាហៅស៏ ២ដង សាកលវិទ្យាល័យហ្សាម៉ាន់ សណ្ឋាគាកាំបូឌីយាណា និងអង្គការមិត្តសំឡាញ់ក្នុងកម្មវិធី សប្បាយសប្បាយ សម្រាប់គ្រួសារ និងមិត្តភក្តិ ដើម្បីរៃអង្គាសថវិកា និងពហុកីឡាដ្ឋានជាតិអូឡាំពិក ។<br>- បុគ្គលិករតាមផ្ទល់ទាំង៣តំបន់ចំនួន ២៤នាក់( ស្រី១៦នាក់) បានទទួលវគ្គរំលឹកស្តីពីដំណើការធ្វើសិប្បកម្មតាមផ្ទះ និង អាជីវកម្មខ្នាតតូច ។<br>- ក្រុមសិប្បកម្មតាមផ្ទះ បានបង្ហាញពីរបៀបធ្វើគ្រាប់អង្កាំពីក្រណាត់ខោខូបូយ ដល់អ្នកស្ម័គ្រចិត្តចំនួន ១២នាក់ មកពីក្រុមហ៊ុនលីវាយ នៅប្រៀន្សអ៊ិនធឺណេសិនណាល នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ។<br>- ក្រុមសិប្បកម្មតាមផ្ទះ បានបង្ហាញពីរបៀបធ្វើគ្រាប់អង្កាំ ដល់សិស្សចំនួន ២៨ នាក់ នៅ សាលា Giving Tree នាថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៣ ។<br>- ប្រធានអាជីវកម្មខ្នាតតូចបានចូលរួមសន្និសិទ្ធស្តីពីធុរកិច្ចសង្គមនៅមជ្ឈមណ្ឌលប្រតិបត្តិការកម្ពុជា-កូរ៉េ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ។<br>- គណៈគ្រប់គ្រងបានចូលរួមកិច្ចប្រជុំជាមួយនិងប្រធានគ្រប់គ្រងដើម្បីពង្រីកដំណើរការ និងគុណភាពរបស់ TREE Alliance ស្តីពីការធ្វើបដិសណ្ឋារកិច្ច ។ |
| **៥.ក្រុមឯកទេសចំនួន ៨ ក្រុមកំពុងផ្តល់ការជួយគាំទ្រកម្មវិធីនៅត្រឹមឆ្នាំ២០១៧** | | |
| **៥.១ ក្រុមឯកទេសលើការការពារកុមារ** | **លទ្ធផលរំពឹងទុកៈ**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ១០០ករណី នឹងត្រូវបានបំពេញ | **លទ្ធផលសម្រេចបានៈ**<br>- ក្នុងឆ្នាំនេះ មានរបាយការណ៏នៃការរំលោភបំពានសរុបចំនួន ១៣៦ករណី ក្នុងនោះ មានៈ ការប្រើអំពើហឹង្សាចំនួន ១១៤ករណី និងការរំលោភផ្លូវចិត្តចំនួន ១៧ករណី ជាដំណោះស្រាយក្រុមការតាមផ្ទល់ បានអន្តរាគមន៏ សម្របសម្រួល និងដោះស្រាយធ្វើ |

<table>
<tr>
<td></td>
<td><br>ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ<br>- ការវាយតម្លៃគោលការណ៍ការពារកុមារនៅក្នុងមណ្ឌលសំចត មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ទាំងអស់<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្ទង់មតិលើការស្នាក់នៅរបស់កុមារ ដែលស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ផ្ទះបៃតង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ(ភោជនីយដ្ឋាន) រៀងរាល់ ៣ខែម្តង<br><br>គាំទ្របច្ចេកទេស<br>- បុគ្គលិក១00% នឹងទទួលការបណ្តុះបណ្តាល និងរំលឹកឡើងវិញលើគោលការណ៍ការពារសិទ្ធិកុមារ<br>- ការបោះឆ្នោតជ្រើសរើសតំណាងកុមារនឹងរៀបចំជារៀងរាល់៦ខែ ក្នុងឆ្នាំ</td>
<td>យ៉ាងណាអោយកុមារមានសុវត្ថិភាព និងធ្វើឱ្យភាពគីទាំងពីរមានភាពល្អប្រសើរឡើង វិញ ដោយឡែកការរំលោភផ្លូវភេទចំនួន 0៥ករណី បានអន្តរាគមន៍ និងចាប់ជនល្មើសបញ្ជូនទៅពន្ធនាគារដោយអាជ្ញាធរមូលដ្ឋាន ។<br><br>ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ<br>- បានរៀបចំការសម្ភាសន៏ចំនួន៤ដង ដែលមាន កុមារ/យុវវ័យ ១១៥នាក់(ស្រី៣៨នាក់) ស្តីពីសេវាកម្មរបស់ អង្គការមិត្តសំឡាញ់ តម្រូវការ និងបញ្ហារបស់ពួកគេ កំឡុងពេលស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នទាំង៣ ។ លទ្ធផលនៃការសម្ភាសន៏បានរាយការណ៏ជូនប្រធាន គម្រោងពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលទៅ ក្នុងផែនការ សកម្មភាព និងយកទៅអនុវត្តដោយ ផ្អែកទៅលើអនុសាសន៏ ។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ និងត្រីមាស ជូនមិត្តសំឡាញ់ ។<br><br>គាំទ្របច្ចេកទេស<br>- បានចុះមូលដ្ឋានចំនួន ២៦៧ដង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលអប់រំ មណ្ឌលសំចត នៅតាមថ្នល់ និងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ដើម្បីពង្រឹងដំណើរការនៃការអនុវត្តន៏គោលការណ៏ ការពារសិទ្ធិកុមារ និងធានាសុវត្ថិភាពដល់កុមារ ។<br>- បុគ្គលិកចំនួន ១១៨នាក់(ស្រី ៥0នាក់) បានចូលរួមវគ្គរំលឹកស្តីពីការអនុវត្តន៏គោលការណ៏ការពារសិទ្ធិកុមារ នៅមិត្តសំឡាញ់ ។<br>- បុគលិកមិត្តសំឡាញ់ចំនួន ១៦(ស្រី0៨នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពី Stress, Distress, Drauma នៅប្រៀន្សអ៊ិនធីណាសិនណល នាថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២0១៣<br>- មន្ត្រីសង្កាត់ចំនួន ១៤នាក់(ស្រី0៨នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៏ ការពារកុមារនៅប្រៀន្សអ៊ិនធីណាសិនណល នាថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២0១៣</td>
</tr>
</table>

| | | |
|---|---|---|
| | **ឧបករណ៏**<br>- នឹងធ្វើបច្ចុប្បន្នភាព និងអនុវត្តគោលការណ៏ការពារសិទ្ធិកុមារ<br>- គោលការណ៏ការពារសិទ្ធិកុមារ នឹងដាក់បង្ហាញនៅគ្រប់មណ្ឌលទាំងអស់<br>- ធានាថាឧបករណ៏ទាំងអស់មាននៅក្នុងមណ្ឌលនីមួយៗ<br>- បង្កើតសៀវភៅណែនាំស្តីពីការចូលរួមរបស់កុមារ ( នៅក្នុងមណ្ឌល គ្រួសារ សហគមន៏ និង សង្គម) និងការណែនាំសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងកុមារ | - បានរៀបចំការបោះឆ្នោតចំនួន២ ដងក្នុងឆ្នាំនេះ<br>- លើកទី ១ កុមារ/យុវវ័យចំនួន ១៩៦ នាក់( ស្រី ៧៨នាក់) បានចូលរួមបោះឆ្នោតជ្រើសរើស តំណាងកុមារ នៅក្លឹបប្រេឡូ នាថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៣ ជាលទ្ធផលកុមារ ចំនួន ០៥នាក់ ( ស្រី០៣នាក់) ។<br>- លើកទី ២ កុមារ/យុវវ័យចំនួន ១៩៧ នាក់( ស្រី ៣២នាក់) បានចូលរួមបោះឆ្នោតជ្រើសរើស តំណាង កុមារនៅក្លឹបប្រេឡូ នាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៣ ជាលទ្ធផលកុមារ ចំនួន ០៥នាក់ ( ស្រី០៣នាក់) ។ កុមារដែលត្រូវបានជាប់ឆ្នោតជាតំណាងកុមារទាំងពីរលើកបានប្រើប្រាស់សិទ្ធិរបស់ ពួកគេក្នុងការចូលរួមនិងលើកនូវកង្វល់របស់ពួកគេជូនគណៈគ្រប់គ្រងនៅក្នុងកិច្ចប្រជុំ ផ្លាស់ប្តូរយោបល់ ។<br>- បានធ្វើបទបង្ហាញស្តីពីគោលការណ៏ការពារកុមារជូនបុគ្គលិកអង្គកា សមត្ថភាពខ្ញុំ នាថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៣<br>**ឧបករណ៏**<br>- បានកែលំអរគោលកាណ៏ការពាកុមារ ។<br>- គោលការណ៏ការពារសិទ្ធិកុមារ បទបញ្ជាផ្ទៃក្នុង សម្ភារៈ និងប្រព័ន្ធរបាយការណ៏បានបិតនៅលើជញ្ជាំងនៃមណ្ឌលអង្គការមិត្តសំឡាញ់ទាំងអស់ ។<br>- គោលការណ៏ការពារកុមារដែលមានស្រាប់កំពុងតែអនុវត្ត ហើយគោលការណ៏ការពារកុមារជារូបភាពកំពុងរង់ចាំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សាបច្ចេកទេស ។<br>- បានព្រាងគោលការណ៏ និងផលវិបាកជារូបភាពនៅក្នុងមណ្ឌល ហើយដាក់ជូនគណៈគ្រប់គ្រងដើម្បីត្រួតពិនិត្យម្តងទៀត ។<br>- សម្ភារៈអប់រំស្តីពីសំបុត្រកំណើតបានបោះពុម្ពឡើងវិញហើយចែកចាយទៅតាមតំបន់<br>**ព្រឹត្តិការណ៏ និងកំណត់សម្គាល់ពិសេសៈ** |

| | | |
|---|---|---|
| | | - បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តន៍ពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ នៅកម្ពុជា នៅសណ្ឋាគារសាន់វេ នាថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៣ ។<br>- បានចូលរួមកិច្ចប្រជុំស្តីពីការគាំទ្រកុមាររងគ្រោះ ដោយការជួញដូរកុមារ នៅគណៈកម្មាធិការលប់បំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា នាថ្ងៃទី ២២ខែកុម្ភៈ ឆ្នាំ២០១៣ ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីផលប៉ះពាល់លើស្ត្រី និងកុមារដោយការស្រូបផ្សែងបារី នៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដែលគាំទ្រដោយអង្គការអភិវឌ្ឍន៍អាត់វ៉ែនទីសកម្ពុជា នាថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៣ ។<br>- បានចូលរួមកិច្ចប្រជុំ ចំនួន៤ដង ស្តីពីទិវាកុមារអន្តរជាតិ បញ្ហាប្រឈម និងសក្តានុពលរបស់សមាជិក សម្ព័ន្ធអង្គការ មិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិ កុមារពីនីតិវិធីបណ្តឹង នៅសម្ព័ន្ធអង្គការមិនមែនរដ្ឋា ភិបាលដើម្បីសិទ្ធិកុមារការទទួលបាន នូវយុត្តិធម៌សម្រាប់កុមាររបស់សមាជិកសម្ព័ន្ធ ។<br>- បានដឹកនាំកុមារ/យុវវ័យចំនួន ០៥នាក់ (ស្រី ០២នាក់) បានចូលរួមកិច្ចប្រជុំស្តីពីសិទ្ធិកុមារនៅអង្គការសមាគមកុមារកម្ពុជាប្រឆាំងទុរភិក្សនិងហឹង្សា អង្គការមណ្ឌលកុមារដើម្បីសុភមង្គល និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការថែទាំជំនួស និង គ្រួសារធម៌ នៅ ក្រសួង ស.អ.រ នាថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៣ ។<br>- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងប្រព័ន្ធការពារកុមារថ្នាក់ជាតិ នៅសណ្ឋាគា កាំបូឌីយ៉ាណា ដែលរៀបចំដោយក្រសួង ស.អ.យ នាថ្ងៃទី២០-២១ខែឧសភា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យចំនួន ២០នាក់ ( ស្រី ១០នាក់) បានចូលរួមទិវាកុមារអន្តរជាតិ នៅ កោះ ពេជ្រ |

| | | |
|---|---|---|
| | | រៀបចំដោយក្រសួង ស.អ.យ និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បី សិទ្ធិកុមារ នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១៣ ។<br>- បានដឹកនាំកុមារចំនួន ០១នាក់ ចូលរួមសិក្ខាសាលាស្តីពី សៀវភៅណែនាំ នៅក្រសួង ស.អ.យ ដែលគាំទ្រដោយអង្គការភ្លែនអន្តរជាតិ និង អង្គការសង្គ្រោះកុមារកម្ពុជា នាថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៣<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍និងបទដ្ឋានអប្បបរមាសម្រាប់ការការពារជនរងគ្រោះ និងការជួញដូរមនុស្ស នៅអង្គការទស្សនៈពិភពលោក នាថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៣<br>- បានរៀបចំយុវវ័យចំនួន ៩៩នាក់(ស្រី ២២នាក់) ចូលរួមបោះឆ្នោតថ្នាក់ជាតិនៅតាមខេត្តកំណើតរបស់ពួកគេ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣<br>- បានចូលរួមកិច្ចប្រជុំសាមញ្ញលើទី ៥០ និង ៥១ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី ១ នៅសាលារាជធានីភ្នំពេញស្តីពីរបាយការណ៍រីកចំរើនប្រចាំខែកក្កដា និងផែនការសម្រាប់ត្រីមាស បន្ទាប់ នាថ្ងៃទី ៣១ ខែកក្កដា និង ២៩ ខែសីហា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យចំនួន ០២នាក់ (ស្រី ០១នាក់)បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារពីនីតិវិធីបណ្តឹង នៅសម្ព័ន្ធអង្គការមិនមែនរដ្ឋា ភិបាលដើម្បីសិទ្ធិកុមារនៅ NGOCRCនាថ្ងៃទី ១៧-១៨ ខែកញ្ញា ឆ្នាំ២០១៣ ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍន៏គោលកាណ៏ការពារកុមារនៅ សណ្ឋាគារ ហ៊ុម៉ារីវ ដែលរៀបចំដោយ AUSAID នាថ្ងៃទី ០៩-១០ ខែកញ្ញា ឆ្នាំ២០១៣<br>- បានចូលរួមសន្និសិទ្ធប្រចាំឆ្នាំ ស្តីពីរបាយការណ៏ NGO CRC ឆ្នាំ ២០១៣ និងផែនការប្រចាំឆ្នាំ ២០១៤ នៅខេត្តបាត់ដំបង នាថ្ងៃទី៥-៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការអនុវត្តអនុសាសន៏របស់គណៈកម្មាធិការ |

| | | |
|---|---|---|
| | | អង្គការ សហ ប្រជាជាតិនៅ សណ្ឋាគារអ៊ីនធឺកងទីដង់តាល់ នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣<br>- បានធ្វើការប៉ាន់ប្រមាណស្តីពីគោលការណ៍ការពារកុមារដែលធ្វើឡើងដោយទីប្រឹក្សា មូលនិធិ AUSAID ហើយមតិយោបល់ គឺវិជ្ជមាន ។ |
| **៥.២ ក្រុមឯកទេស វេជ្ជសាស្ត្រ** | **លទ្ធផលរំពឹងទុកៈ**<br>- សេវាព្យាបាលនិងសង្គ្រោះបឋមចំនួន ៩៦,000 នឹងផ្តល់ជូនកុមារ/យុវវ័យ ក្នុងនោះ មានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ២៧,000 សេវា<br>- កុមារ/យុវវ័យចំនួន ៧៥0នាក់ នឹងបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ១0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣<br>- អាណាព្យាបាលដែលផ្ទុក មេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ៣0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣<br>- កុមារ/យុវវ័យចំនួន ៣00នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br>- អាណាព្យាបាលចំនួន ៣00នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br>- កុមារចំនួន ៣៥0នាក់ នឹងបញ្ជូនទៅធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់<br>- កុមារ/យុវវ័យចំនួន ៥00នាក់ ដែលឆ្លងនិងរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺអេដស៍ នឹងទទួលបានសេវានៅមិត្តសំឡាញ់ ឬតាមរយៈមិត្តសំឡាញ់<br>- កុមារ/យុវវ័យចំនួន ១១0នាក់ នឹងទទួលថ្នាំពន្យាជីវិត(ARV) និងការព្យាបាលជម្ងឺឱកាសនិយម (OI) | **លទ្ធផលសម្រេចបានៈ**<br>- សេវាព្យាបាល និងសង្គ្រោះបឋមចំនួន ១១៦,៨៧៤( ស្រី ៤២,៨៩៥) បានផ្តល់ជូនកុមារ/យុវវ័យក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ៣៧,៧២៦ ( ស្រី ៨,៥១៤) សេវា ។<br>- កុមារ/យុវវ័យចំនួន ៨៤១នាក់( ស្រី ៣៧១នាក់) បានបញ្ជូនទៅព្យាបាលមន្ទីរពេទ្យ ។<br>- កុមារ/យុវវ័យផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ១៥នាក់ (ស្រី0៥) បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- អាណាព្យាបាលដែលផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ២៧នាក់ (ស្រី១៨នាក់) បានទទួលការ ព្យាបាលនៅមន្ទីរពេទ្យ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យចំនួន ២៩១នាក់ (ស្រី១១៣នាក់) បានទទួលការព្យាបាលជម្ងឺកាមរោគពីគ្លីនិករបស់មិត្តសំឡាញ់ទាំងអស់ ។<br>- អាណាព្យាបាលចំនួន ៤៥១នាក់( ស្រី ៣៩២នាក់) បានទទួលការព្យាបាលជម្ងឺកាមរោគពីគ្លីនិករបស់មិត្តសំឡាញ់ទាំងអស់ ។<br>- កុមារ/យុវវ័យចំនួន ៦0៧នាក់(ស្រី១៨៥នាក់) បាន បញ្ជូនទៅធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ចាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០១៣ ។<br>- កុមារ/យុវវ័យចំនួន ៦៧៤នាក់ ( ស្រី ៣១៦)ដែលឆ្លងនិងរងផលប៉ះពាល់ មេរោគអេដស៍/ជម្ងឺអេដស៍ បានទទួលសេវានៅមិត្តសំឡាញ់ ឬតាមរយៈមិត្តសំឡាញ់ ចាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០១៣ ។ |

| | | |
|---|---|---|
| | - អាណាព្យាបាលចំនួន ៣០០នាក់ ដែលទទួលរងផលប៉ះពាល់ នឹងទទួលថ្នាំពន្យាជីវិត (ARV) និងការព្យាបាលជម្ងឺ ឱកាសនិយម (OI) តាមរយៈមិត្ត សំឡាញ់<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធត្រួតពិនិត្យនិងប្រមូលទិន្នន័យគឺជាសូចនាករលក្ខណៈស្តង់ដា នៃកម្មវិធីប្រៀន្យ អ៊ិនធឺណាសិនណលសម្រាប់សកម្មភាពសុខាភិបាល<br>- ការវាយតម្លៃលើការថែរក្សាផ្នែកសុខភាពនៅក្នុងគម្រោងទាំងអស់មានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយអ្នកឯកទេសហ៊ីវ/អេដស៍ក្នុងរយៈពេល១ឆ្នាំ<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br><br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកវេជ្ជសាស្ត្រទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាលយ៉ាងទៀងទាត់<br>- បុគ្គលិកចំនួន ៥០ នាក់នឹងទទួលបានការបណ្តុះបណ្តាលស្តីពី ថែទាំសុខភាពមាត់ធ្មេញ និងសង្គ្រោះបឋម<br>- ជំនួយបច្ចេកទេស នឹងផ្តល់ជារៀងរាល់សប្តាហ៍តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>- ពង្រឹងកិច្ចសហការរវាងបុគ្គលិកសុខាភិបាល និងអ្នកគ្រប់គ្រងករណី | - កុមារ/យុវវ័យចំនួន១០៣នាក់( ស្រី ៤៨នាក់) បានទទួលថ្នាំពន្យាជីវិត (ARV) និងការព្យាបាលជម្ងឺឱកាស និយម (OI) ចាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០១៣ ។<br>- អាណាព្យាបាលចំនួន ២៧២នាក់ ( ស្រី ១៨១នាក់) ដែលទទួលរងផលប៉ះ ពាល់ មេរោគអេដស៍/ជម្ងឺ បានទទួលសេវាសង្គម រួមមាន អាហារ ការជួលផ្ទះ និងការគាំទ្រអាជីវកម្មខ្នាតតូច នៅអង្គការមិត្តសំឡាញ់ ចាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០១៣ ។<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- តាមរយៈការចុះមូលដ្ឋានបានតាមដាន យ៉ាងទៀងទាត់ លើសេវាគ្លីនិកទាំងអស់អោយមានអនាម័យ ល្អបន្ទប់ស្អាត ទម្រង់អង្កេតរបស់កុមារត្រូវបានបំពេញ និង កន្លែងទុកថ្នាំត្រូវបានរៀបចំយ៉ាងរៀបរយ ។<br>- បានត្រួតពិនិត្យសុខភាពកុមារ/យុវវ័យ ដែលចូលរៀននៅអង្គការមិត្តសំឡាញ់ និងពេលបញ្ជូនទៅគ្រួសារ ឬប្រកបមុខរបរមានចំនួន ៣៩៤នាក់( ស្រី ៨៨នាក់) ។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ ត្រីមាសដើម្បីផ្ញើជូនមិត្តសំឡាញ់ មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងក្រសួងសុខាភិបាល ។<br><br>**គាំទ្របច្ចេកទេស**<br>- បានចុះមូលដ្ឋានចំនួន ១៣១ដង ក្នុង៤តំបន់ នៃក្រុមតាមផ្ទល់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ផ្ទះបៃតង និងមណ្ឌលសំចតចល័ត ដើម្បីជួយអ្នកគ្រប់គ្រងករណី និងប្រធានតំបន់ក្នុងការគាំទ្រផ្នែកសុខភាពដល់កុមារ/យុវវ័យ និងគ្រួសារតាមតំបន់គោលដៅ ។<br>- បានជួយព្យាបាល គាំទ្រផ្លូវចិត្ត និងដោះស្រាយបញ្ហាបានចំនួន ៧៣ ករណី ដោយអ្នកគ្រប់គ្រងករណីនិង ប្រធានក្រុមតំបន់នីមួយៗ ដែលគាំទ្រដោយឯកទេសវេជ្ជសាស្ត្រ ។ |

| | | |
|---|---|---|
| | - ពិនិត្យឡើងវិញ និងបញ្ចូទិញសម្ភារៈវេជ្ជសាស្ត្រតាមតម្រូវការរបស់ក្រុមការងារ<br><br>**ឧបករណ៍**<br>- សៀវភៅណែនាំ នឹងរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br><br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៣៥នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះណ្តាលក្នុងមួយឆ្នាំ<br>- ទំនាក់ទំនងជាមួយរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាព | **ឧបករណ៍**<br>- មិត្តសំឡាញ់បានចុះអនុស្សារណៈជាមួយក្រសួងសុខាភិបាលស្តីពី ការគាំពារសុខភាព កុមារ/យុវវ័យ ងាយរងគ្រោះនិងបាត់បង់ឱកាសរបស់គ្រួសារនិង សហគមន៍ របស់ពួកគេនៅក្នុងប្រទេសកម្ពុជាសម្រាប់អនុវត្តបន្តរយៈពេល ៣ឆ្នាំ ។<br>- គោលការណ៍ព្យាបាល និង សេវា ត្រូវបានកែលម្អហើយអនុមត័ដោយនាយកកម្មវិធី<br>- គោលការណ៍សង្គ្រោះបឋមបានពង្រាងហើយផ្ញើជូនទៅ ប្រ៊ោន្យអ៊ុនធីណាសិនណល ។<br>- គោលការណ៍ព្យាបាលអ្នកញៀនស្រា បានទទួលការអនុមត័ពីនាយកកម្មវិធី ។<br>- បរិក្ខាថ្នាំពេទ្យរបស់អង្គការមិត្តសំឡាញ់បានធ្វើការដេញថ្លៃ នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ហើយ ឱសថស្ថានប៉ាស៊ីហ្វិកបានចុះកិច្ចសន្យាផ្គត់ បរិក្ខាថ្នាំពេទ្យពេញ១ឆ្នាំក្នុង ឆ្នាំ២០១៤នេះ ។<br><br>**ដៃគូ**<br>**<u>ការប្រជុំ និងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូៈ</u>**<br>- បន្តសហការជាមួយវេជ្ជបណ្ឌិត នៅមជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យគន្ធាបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យបង្អែកក្រុង និង មជ្ឈមណ្ឌលជាតិប្រយុទ្ធ & ជំងឺអេដស៍សើស្បែក &កាមរោគ ដើម្បីគាំទ្រ និងព្យាបាលដល់កុមារ និងយុវវ័យ ។<br>- បានចូលរួមកិច្ចប្រជុំប្រចាំខែជាមួយអង្គការម៉េឌីខាំ ចំនួន៨ដង ស្តីពី ជំងឺគ្រុនចាញ់ ប្រព័ន្ធការពាររាងកាយចុះខ្សោយ អាហារូបត្ថម្ភ និងជំងឺរបេង ដែលមានកិច្ចសហការជាមួយអង្គការដៃគូផ្សេងទៀត នៅការិយាល័យ អង្គការម៉េឌីខាំ ។<br>- កុមារនៅមជ្ឈមណ្ឌលអប់រំចំនួន ៣០៩ (ស្រី ១១២នាក់) បានគាំទ្រលើការព្យាបាល និង |

| | | |
|---|---|---|
| | | ថែទាំសុខភាពមាត់ធ្មេញពីអង្គការ One 2 One នៅមន្ទីរពេទ្យព្រះកិតុមាលា ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការបំលាស់ប្តូរតិរយាបទសង្គមនិង អន្តរាគមន៏សម្រាប់អេដស៏/ជំងឺ និងសុខភាពបន្តពូជ ផ្លូវភេទ និងការរស់រានមានជីវិតរបស់កុមារ នៅក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៣ ។<br>- បុគ្គលិកពេទ្យ ០១នាក់ បានទទួលវគ្គបណ្តុះបណ្តាល ស្តីពីការប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៏ រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៏សើស្បែក និងកាមរោគ នាថ្ងៃទី៤-៨ ខែមីនា ឆ្នាំ២០១៣ ។<br>- បានចូលរួមកិច្ចប្រជុំសន្និបាតបូកការងារប្រចាំឆ្នាំ របស់អង្គការខ្មែរបំរើសុខភាពប្រជាជន និងសម្ពោធន៏អង្គការខ្មែរបំរើសុភាពប្រជាជន នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ។<br>- យុវ័វយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន៨៤នាក់ ( ស្រី៤៧នាក់) បានទទួលថ្នាំ បង្ការតេតាណូស និងកុមារនៅមណ្ឌលអប់រំចំនួន ០៦ នាក់ ( ស្រី ០៣នាក់) បានទទួលថ្នាំ បង្ការ Diphtheria, Pertussis តេតានូស ជំងឺរលាកថ្លើមប្រភេទបេ HIB ពីកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ នៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃ ២៥ ខែមីនា ឆ្នាំ២០១៣ ។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ១៧នាក់ (ស្រី០៨នាក់) បានទទួលវគ្គបណ្តុះបណ្តាល ស្តីពីជំងឺគ្រុនឈាម និងមូលដ្ឋានគ្រឹះការថែរក្សាមាត់ធ្មេញ នៅក្លឹបហ្រ្វេន្ស នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ។<br>- បានចូលរួមពិធីសម្ពោធ យុទ្ធនាការលើកកម្ពស់សុខភាពកុមារឥឡូវនេះ នៅសណ្ឋាគារអាំងទែកង់ទីណង់តាល់ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញ អំពីច្បាប់និងលើគោលនយោបាយ នៃការរីករាលដាលមេរោគអេដស៏/ជំងឺអេដស៏ នៅណាហ្គាវើល នាថ្ងៃទី១៦-១៧ ខែកញ្ញា ឆ្នាំ២០១៣ |

| | | |
|---|---|---|
